# ២.៤ ការរៀនមួយជីវិត

តើការរៀនសូត្ររបស់អ្នកបញ្ចប់នៅពេលអ្នករៀនចប់មធ្យមសិក្សា មធ្យមសិក្សាបច្ចេកទេស ឬសាកលវិទ្យាល័យឬ? ប្រហែលជាការអប់រំផ្លូវការរបស់អ្នកត្រូវបញ្ចប់នៅពេលអ្នកបោះចោលសៀវភៅ និងចូលប្រលូកក្នុងពិភពខាងក្រៅដើម្បីរកការងារធ្វើ។ ប៉ុន្តែ តើការរៀនសូត្ររបស់អ្នកត្រូវបញ្ចប់នៅពេលនោះមែនឬ? ពាក្យស្លោកបុរាណមួយពោលថា "យើងតែងរៀនអ្វីដែលថ្មីជារៀងរាល់ថ្ងៃ"នៅតែត្រឹមត្រូវសំរាប់យើងគ្រប់គ្នាទោះយើងមានការងារធ្វើត្រូវជំនាញយើងក៏ដោយ។



តាមវិធីងាយស្រួល ការបន្តសន្សំបទពិសោធន៏គឺជាអត្ថន័យនៃពាក្យរៀនមួយជីវិត។ នៅពេលដែលថាយើងមិនបានចូលរៀនជាផ្លូវការនៅកន្លែងណាមួយ យើងមិនដែលឈប់ទទួលបានចំណេះដឹងថ្មីៗតាមរយៈការងារ និងតាមការរស់នៅរបស់យើងនោះទេ។ ចំណេះដឹងនេះអាចទទួលបានក្រៅផ្លូវការតាមរយៈទំនាក់ទំនងជាមួយមិត្តភក្តិ ឬសហសេវិករួមអាជីព ឬអាចជាផ្លូវការតាមរយៈសិក្ខាសាលា និងសន្និសីទ ឬអាចជាការបណ្តុះបណ្តាលតាមរយៈការងារអនុវត្តជាក់ស្តែង "ធ្វើការផង រៀនផង"។



គិតឡើងវិញពីជំនាញរបស់អ្នក ។ តើអ្នករៀនប្រើកំព្យូទ័រដោយរបៀបណា? អ្នករៀនចេះកុំព្យូទ័រដោយសារអ្នកធ្លាប់បានប៉ះ ឬ ធ្លាប់វាយកុំព្យូទ័រលេង? តើអ្នកមានការបណ្តុះបណ្តាលនៅកន្លែងធ្វើការឬទេ? ឬវិធីអ្វីក៏ដោយឲ្យតែអ្នកប្រើគឺជាបទពិសោធន៏ជាក់ស្តែងរបស់អ្នក?

section 2.4.qxp 21/12/2004 9:43 AM Page 2



# ២.៤ ការរៀនមួយជីវិត

## ២.៤.១. ការមានការងារធ្វើ

សញ្ញាប័ត្រសាកលវិទ្យាល័យមិនប្រាកដថាអាចធ្វើឲ្យនរណាម្នាក់ជាអ្នកមានសមត្ថភាពខ្ពស់បំផុតសំរាប់កងារនោះទេ។ នៅប្រទេសឥណ្ឌា សាលាបណ្តុះបណ្តាលវិជ្ជាជីវៈBarefootបានបណ្តុះបណ្តាលស្ត្រីក្នុងភូមិឲ្យក្លាយជាវិស្វករធ្វើអណ្តូងស្នប់ និងបុរសឲ្យក្លាយជាវិស្វករតម្លើងអគ្គិសនីថាមពលព្រះអាទិត្យ។ ជំនាញទាំងនេះមិនត្រឹមតែមានតម្លៃសំរាប់បុគ្គលម្នាក់ៗនោះទេ តែក៏ជួយអភិវឌ្ឍន៍សហគមន៍ និងជួយដោះស្រាយបញ្ហាបានត្រឹមត្រូវ និងទាន់ពេលវេលាផងដែរ។ "ការអប់រំបែបនេះហៅថាការអប់រំដើម្បីបានការងារធ្វើ"។ នេះគឺជាផ្នែកមួយនៃ គោលដៅអប់រំសំរាប់ទាំងអស់គ្នា ។

អ្នកសារព័ត៌មានតែងប្រមូលបានរឿងគួរឲ្យចាប់អារម្មណ៍ និងមានផលប្រយោជន៍សំរាប់ពលរដ្ឋទូទៅនៅក្នុងសហគមន៍។ អ្នកអានសារព័ត៌មាន អ្នកមើលទូរទស្សន៍ និងអ្នកស្តាប់វិទ្យុ ចូលចិត្តស្តាប់ អាន និងមើលវិធីសាស្ត្រអប់រំសាមញ្ញៗ ប៉ុន្តែ អាចសំរេចបំណងរបស់គេបាន។ រឿងល្អៗដែលមានជោគជ័យអាចទាក់ទាញអារម្មណ៍អ្នកមើល អ្នកស្តាប់ចង់ចាប់យកជំនាញនេះដែរ។



# ២.៤ ការរៀនមួយជីវិត

## ២.៤.២. ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

នៅក្នុងប្រទេសជាច្រើន ជាពិសេសប្រទេសឧស្សាហកម្ម បុគ្គលិកជំនាញមានសមត្ថភាពខ្ពស់ ។ ទោះជានិស្សិតក្មេងៗជាច្រើនបន្តការសិក្សានៅសាកលវិទ្យាល័យបន្ទាប់ពីបញ្ចប់មធ្យមសិក្សាទុតិយភូមិក៏ដោយ ក៏មាននិស្សិតមួយចំនួនចង់រៀនជំនាញវិជ្ជាជីវៈក្នុងផ្នែកផ្សេងៗ ដូចជា ជាងឈើ ជាងរៀបឥដ្ឋ ជាងកំបោរ ជាងលូទឹក ជាងម៉ាស៊ីន និងជំនាញប្រហាក់ប្រហែលគ្នាផ្សេងៗទៀតដែរ ។ តើនេះជាមូលហេតុដែលនិស្សិតក្មេងៗយល់ឃើញថា ធ្វើការងារដោយប្រើដៃអន់ជាងការងារដែលប្រើបញ្ញាមែនទេ? ឬដោយហេតុថា ការងារការិយាល័យ ឬការងារគ្រប់គ្រងជាការងារដែលទទួលបានប្រាក់ខែច្រើនជាង?

គិតពីស្ថានភាពនេះនៅក្នុងប្រទេសរបស់អ្នក ។ តើអ្នកដែលរៀនចប់សាកលវិទ្យាល័យមានផ្សារការងារច្រើនជាងអ្នកដែលរៀនចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈឬទេ? បើអញ្ចឹងមែន ហេតុអ្វី? តើមានកង្វះខាតអ្នកមានជំនាញការងារហត្ថកម្មដែរឬទេ? តើកង្វះខាតនេះនឹងប៉ះពាល់យ៉ាងណាដល់សង្គមជាតិទៅថ្ងៃអនាគត? តើនៅប្រទេសអ្នក គេបញ្ចុះបញ្ចូលមនុស្សឲ្យចាប់យកមុខរបរអ្វីមួយដោយរបៀបណា?

**ឯកសារយោង :**

*2_4_occupation_link.pdf from CD ROM)* that are a vital necessity to the

**community, such as building trades or farming?**

*(Refer: Article - Reforming vocational education to reform the agricultural sector in Kyrgyzstan.htm from CD ROM)*

# ២.៤ ការរៀនមួយជីវិត

## អប់រំដើម្បីការងារ

### បដិវត្តន៏ជំនាញនៅក្នុងការងារផលិតកម្មនៅអាហ្វ្រិកខាងត្បូង

**ដោយ By Farah Khan**

**Inter Press Service**

ទីក្រុងខេបថោន ប្រទេសអាហ្វ្រិកខាងត្បូង ខែមីនា ថ្ងៃទី ២៤ (IPS)– រដ្ឋាភិបាលអាហ្វ្រិកខាងត្បូង កំពុងខិតខំឲ្យមាន "បដិវត្តន៏ជំនាញ" ដើម្បីដោះស្រាយបញ្ហាដែលកើតឡើងពីការអប់រំមួយដែលមានការប្រកាន់ពូជសាសន៏ លើកំលាំងពលកម្មដែលគ្មានជំនាញ និងទទួលប្រាក់កំរៃយ៉ាងតិចបំផុត និងដែលជាការគំរាមកំហែងដល់ការអភិវឌ្ឍន៏ជាតិ ។

បដិវត្តន៏ជំនាញគឺជាពាក្យដែលរដ្ឋមន្ត្រីក្រសួងពលកម្ម គឺលោក Membathisi Mdladlana ប្រើដើម្បីពិណនាអំពីផែនការជាតិ ដើម្បីធ្វើឲ្យស៊ីសង្វាក់គ្នារវាងកន្លែងបណ្ដុះបណ្ដាល និងតម្រូវការក្នុងជីវភាពជាក់ស្តែងដើម្បីឲ្យមានសេដ្ឋកិច្ចរីកចំរើន និងដើម្បីឲ្យពលករបានអភិវឌ្ឍន៏ចំណេះដឹងដើម្បីរកបានប្រាក់កំរៃឲ្យបានច្រើនជាងមុន ។

ការផ្តួចផ្តើមគំនិតនេះគឺទាក់ទងនឹងប្រាក់ ១ ភាគរយ ដែលបានពីរដ្ឋាភិបាល និងពាណិជ្ជករដើម្បីផ្តល់ប្រាក់សំរាប់អាជ្ញាធរអប់រំចំនួន ២៧ កន្លែងដែលផ្តល់ការបណ្ដុះបណ្ដាលជំនាញ។

អាជ្ញាធរនេះបន្ទឹផ្នែកសំខាន់ជាងគេបង្អស់នៅក្នុងវិស័យសេដ្ឋកិច្ច និងកត់សំគាល់ជំនាញចាំបាច់ពង្រឹងការប្រកួតប្រជែងនៅក្នុងឧស្សាហកម្មនីមួយៗ ។ កម្មករនឹងទទួលបានការបណ្ដុះបណ្ដាលតាមស្ថានភាពជាក់ស្តែង ។

បើសិនជាទទួលបានជោគជ័យមែន ការបណ្ដុះបណ្ដាលនេះនឹងនាំមកនូវពលករដែលមានជំនាញខ្ពស់ និងជំរុញឲ្យមានការរីកចំរើនផ្នែកសេដ្ឋកិច្ចជាមិនខាន ។

លោក Mdladlana មានប្រសាសន៏ថា "កម្មវិធីនេះជាកម្មវិធីដែលគួរឲ្យកត់សំគាល់ ជាពិសេសកម្មវិធីនេះមានឥទ្ធិពលខ្លាំងលើសេដ្ឋកិច្ចនិងលើកកំពស់ជីវភាពពលរដ្ឋឲ្យកាន់តែល្អប្រសើរឡើង"។

# ២.៤ ការរៀនមួយជីវិត

## អប់រំដើម្បីការងារ

ទោះបីជាគោលដៅនេះគឺសំរាប់ថ្ងៃអនាគតក៏ដោយ ក៏គោលនយោបាយអភិវឌ្ឍន៏ជំនាញមានគោលបំណងដោះស្រាយបញ្ហាអតីតកាលផងដែរ ។ អ្នកធ្វើគោលនយោបាយកាលពីជំនាន់បែងចែកវណ្ណៈបានកំណត់ថា ជនជាតិស្បែកខ្មៅកើតមកជាអ្នករកអុស និងដងទឹក ។

ក្នុងទស្សនៈប្រហាក់ប្រហែលគ្នានេះដែរ កូនរបស់ពួកជនជាតិស្បែកខ្មៅមិនត្រូវបានគេផ្តល់ឱកាសឲ្យបានទទួលការអប់រំទេ ។ រដ្ឋាភិបាលបែងចែកវណ្ណៈបានចំណាយពេលវេលាប្រហែលពី ៤ ទៅ ៧ ដងជាមួយកូនជនជាតិស្បែកសច្រើនជាងកូនពួកស្បែកខ្មៅ។

រដ្ឋប្រជាធិបតេយ្យដែលចាប់ផ្តើមនៅឆ្នាំ ១៩៩៤ មានឥទ្ធិពលខ្លាំងក្លាណាស់ ។ កម្មករពុំមានជំនាញទេ ហើយអ្នករកការងារធ្វើមិនអាចរកការងារធ្វើបាននៅក្នុងវិស័យសេដ្ឋកិច្ច ដូចជាផ្នែកព័ត៌មានវិទ្យា និងសេវាកម្មហិរញ្ញវត្ថុ ពីព្រោះពួកគេភាគច្រើនគឺជាអនក្ខរជនវិជ្ជាជីវៈ។

អ្នកដែលបាត់បង់ការងារនៅក្នុងឧស្សាហកម្ម ដូចជា រ៉ែ និងការផលិតក្រណាត់ មិនអាចទទួលបានការងារធ្វើវិញទេ ពីព្រោះពួកគេពុំមានជំនាញច្រើន។ អ្នកវិនិយោគក្នុងស្រុក និងបរទេសមិនដាក់វិនិយោគទេ ដោយហេតុថាពលករមិនសូវមានជំនាញ។

Mdladlana មានប្រសាសន៏ថា "មានប្រជាជនតិចណាស់ដែលមានចំណេះដឹង និងជំនាញក្នុងការបង្កើន ផលិតផលរបស់ជាតិ និងពង្រីកធនធាន ដែលប្រទេសត្រូវការដើម្បីបំបាត់វិសមភាព និងភាពក្រីក្រ ។ គម្រោងសាកល្បងមួយនៅ Kwazulu-Natal កំពុងតែទទួលបានលទ្ធផលល្អ ។ ការបណ្តុះបណ្តាលផ្នែកទេសចរណ៍ និងបដិសណ្ឋារកិច្ចកំពុងបណ្តុះបណ្តាលយុវជនក្មេងៗចំនួន ៦០០០ នាក់ ។

ពួកគេធ្វើការផ្នែករៀបចំគ្រែ និងអាហារពេលព្រឹក និងចាត់ចែងរមណីដ្ឋានទេសចរសេដ្ឋកិច្ច ។ ការងាររបស់គេលំបាក ហើយទទួលបានប្រាក់កំរៃតិច តែពួកគេឧស្សាហ៍ ហើយធ្វើការទាន់ពេលវេលា ។ ពួកនេះទទួលបានជំនាញពិតប្រាកដសំរាប់ការប្រកបរបរចិញ្ចឹមជីវិតទៅថ្ងៃក្រោយ។

C·O·L

# ២.៤ ការរៀនមួយជីវិត

## អប់រំដើម្បីការងារ

វាមិនគ្រាន់តែជាការបណ្តុះបណ្តាលសហគ្រិនទេ ប៉ុន្តែថែមទាំងបណ្តុះបណ្តាលអ្នកវិនិយោគជាមួយនឹងកម្មករដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវទៀតផង ។ នៅឯ Port Elizabeth ទីក្រុងខេបថោនប៉ែកខាងកើតវិញ កម្មករកំពុងតែទទួលការបណ្តុះបណ្តាលដើម្បីធ្វើជាបុគ្គលិកនៅតាមរោងចក្រ South African Breweries។

អ្នកធ្វើគោលនយោបាយសង្ឃឹមថា អាហ្វ្រិកខាងត្បូងអាចចូលរួមក្នុងដំណើរការសកលនីកម្មនៅកន្លែងដែលមានការរីកចំរើនផ្នែកសេដ្ឋកិច្ច ។ ពួកគេជឿជាក់ថា បើសិនជាកម្មករមានជំនាញគ្រប់គ្រាន់ និងធ្វើការបានរីកចំរើន ពួកគេអាចកែលំអជីវភាពរស់នៅ គុណភាពការងារ និងការផ្លាស់ប្តូរមុខតំណែងក្នុងការងារ។

សហគមន៍អ៊ឺរ៉ុបផ្តល់ជំនួយហិរញ្ញវត្ថុមួយចំនួនធំសំរាប់បណ្តុះបណ្តាលជំនាញថ្មី និងបណ្តុះបណ្តាលអំពីខ្លឹមសារគោលនយោបាយ ។ នេះគឺជាប្រាក់ជំនួយចំនួន ២៣៦ លាន រ៉ាន់ (Rand ជាប្រាក់អាហ្វ្រិកខាងត្បូង ១ ដុល្លា = ៦.៣ រ៉ាន់) ដែលជាប្រាក់ជំនួយដ៏ធំបំផុតរបស់សហគមន៍អឺរ៉ុបផ្នែកកម្មវិធីជំនួយបច្ចេកទេស។

លោក Mdladlana មានប្រសាសន៍ថានេះគឺជាជំនួយដែលនឹងនាំមកនូវការអភិវឌ្ឍន៍ជាសកល ។ អាហ្វ្រិកខាងត្បូងនឹងក្លាយជាដៃគូពាណិជ្ជកម្មដ៏ពិតប្រាកដ ដោយពង្រីកផ្លូវជាតិបុរាណរបស់ខ្លួនទៅដល់បណ្តាប្រទេសនៅប៉ែកខាងជើងដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរជាសារវ័ន្តរវាងខាងជើង និងខាងត្បូង និងនៅក្នុងអាហ្វ្រិក និងអាហ្វ្រិកខាងត្បូង ។

៨០ ភាគរយនៃប្រាក់សំរាប់បណ្តុះបណ្តាល ដែលរដ្ឋាភិបាលប្រមូលបាននឹងផ្តល់ឲ្យអាជ្ញាធរទទួលខុសត្រូវបណ្តុះបណ្តាល ឬត្រូវឲ្យជាប្រាក់ឧបត្ថម្ភដល់ក្រុមហ៊ុនណាដែលមានកម្មវិធីបណ្តុះបណ្តាល។ ចំណែកប្រាក់ដែលនៅសល់នឹងត្រូវប្រើប្រាស់សំរាប់ប្រជាជនដែលមានសេដ្ឋកិច្ចអន់ថយ និងជួបការលំបាកសំរាប់បង្កើតមុខរបររកស៊ីតូចតាចតាមគ្រួសារ ។

# ២.៤ ការរៀនមួយជីវិត

## អប់រំដើម្បីការងារ

ផែនការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍ជំនាញនឹងត្រូវអនុវត្តក្នុងរយៈពេលច្រើនឆ្នាំ ត្រូវបានបង្កើតរួចហើយ ហើយប្រាក់ដែលរដ្ឋប្រមូលបានអាចចាត់ចែងសំរាប់គម្រោងសាកល្បងជាច្រើន។

អត្ថបទនេះត្រូវរក្សាសិទ្ធិគ្រប់យ៉ាង ហើយការដកស្រង់ត្រូវមានច្បាប់អនុញ្ញាតពី និងយល់ព្រមពី Inter Press Service ។

# ២.៤ ការរៀនមួយជីវិត

## បណ្តុះបណ្តាលវិជ្ជាជីវៈ

សាលាបណ្តុះបណ្តាលវិជ្ជាជីវៈបង្រៀនជំនាញមីក្រូសេដ្ឋកិច្ចនៅ Ecuador

ដោយ Kintto Lucas
Inter Press Service

គីតូ ខែមេសា ថ្ងៃទី ៤ (IPS)– Ecuador កំពុងកែទំរង់ប្រព័ន្ធអប់រំមនុស្សពេញវ័យដោយពិនិត្យមើលកម្មវិធីសិក្សាឡើងវិញសំរាប់សិស្សចំនួន ៦៥០០០ នាក់ នៅក្នុងសាលបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ១៧០០ មុខ ។ ផែនការដែលកំពុងអនុវត្តដោយក្រសួងអប់រំបានទទួលជំនួយពីUNESCO ។

មណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈភាគច្រើននៅ Ecuador (ប្រហែល ១០០០) បង្រៀនមុខវិជ្ជាពាណិជ្ជកម្ម និងសិប្បកម្ម ដូចជា កាត់ដេរសំលៀកបំពាក់ ហើយមួយចំនួនទៀតជាសាលារបស់សហគមន៍ ។

តាមពិតនៅក្នុងផែនការថ្មីនេះ សំលៀកបំពាក់ដែលធ្វើដោយសិស្សនៅក្នុងថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈនេះនឹងលក់តាមទីផ្សារ។ រហូតមកដល់ពេលនេះ សិស្សអាចរក្សាទុកអ្វីដែលគេបានផលិតសំរាប់ផ្ទាល់ខ្លួន និងសំរាប់គ្រួសារ។ គម្រោងថ្មីកំពុងតែអនុវត្តដោយការិយល័យជាតិដើម្បីការអប់រំប្រជាប្រិយដែលឥឡូវនេះកំពុងតែបណ្តុះបណ្តាលបុគ្គលិករបស់សាលាចំនួន ៥០ ដំបូងនៅពេលដែលកម្មវិធីមូលដ្ឋានកំពុងត្រូវបានគេរៀបចំ ។

កម្មវិធីដែលកំពុងតែអនុវត្តនៅខែនេះក្នុងថវិកាចំនួន ៤០០០០ ដុល្លាបានមកពីក្រសួងអប់រំនឹងធ្វើឡើងក្នុងសាលាវិជ្ជាជីវៈចំនួន ៥០ នៅតំបន់ភ្នំ និងតំបន់ព្រៃអាម៉ាសូននៃ Ecuador និងបន្តបើកបន្ថែមចំនួន ៥០ ទៀតនៅខែឧសភានៅតាមតំបន់ឆ្នេរ ។

អ្នកផ្តល់ជំនួយផ្សេងទៀតរួមមាន : Organisation of Ibero-American States for Education, Science and Culture (OEI), the National Financial Corporation (CFN) and the Ministry of Labour and Social Action.

# ២.៤ ការរៀនមួយជីវិត

## បណ្តុះបណ្តាលវិជ្ជាជីវៈ

គំនិតតំបូងនៃការផ្តួចផ្តើមនេះគឺថា សិស្សអាចរៀនជំនាញជំនួញផ្សេងទៀត ដូចជា កាត់ដេរ សំលៀកបំពាក់ ថែរក្សា និងកែសម្ផស្ស និងជាងឈើ នៅវិទ្យាស្ថានបណ្តុះបណ្តាល ពួកគេនឹងធ្វើការនៅក្នុងមីក្រូសហគ្រិនដែលត្រូវបានបង្កើតឡើងដោយមានការគាំទ្រពីសាលាដែលពួកគេបានទទួលការបណ្តុះបណ្តាល ។ CFN នឹងបង្រៀនជំនាញទីផ្សារដើម្បីណែនាំមីក្រូសហគ្រិន និងជួយធានានិរន្តរភាពនៃមុខជំនួញ។

គោលបំណងចង់ឲ្យអ្នករៀនចប់មានជំនាញដែលអាចបង្កើតឧស្សាហកម្មខ្នាតតូចនៅពេលគេរៀនចប់។ ដោយហេតុថាសិស្សជាច្រើនដែលរៀននៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈគឺជាសិស្សមិនចេះអក្សរ រៀនក្នុងកម្មវិធីមីក្រូសេដ្ឋកិច្ច ។ អង្គការ UNESCO និង OEI ជាអង្គការសហការជាមួយក្រសួងបានផ្តល់ប្រាក់ចំនួន ៤០០០០ ដុល្លា សំរាប់ការខិតខំប្រឹងប្រែងអភិវឌ្ឍន៍កម្មវិធីនេះ ។

Astudillo បានបញ្ជាក់ថា កម្មវិធីនេះក៏មានគោលបំណងលុបបំបាត់អណក្ខរកម្មនៅ Ecuador ដែលជាកន្លែងមានប្រជាជន ១២ភាគរយនៃប្រជាជន ១១.៥ លាននាក់ មិនចេះអាន និងសរសេរ ជាប្រទេសដែលមានអត្រាអនក្ខរកម្មខ្ពស់ជាងគេនៅអាមេរិកឡាទីន ។

ដើម្បីពេញលក្ខណៈជាអ្នកចូលរួម : សាលាត្រូវមានហេដ្ឋារចនាសម្ព័ន្ធ និងយន្តការ និងសំភារៈផ្សេងៗទៀតសំរាប់បំពេញលក្ខខណ្ឌការងារ បុគ្គលិកដែលទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ហើយយ៉ាងហោចណាស់មានសិស្ស ១០០ នាក់ ។

ហេតុផលសំខាន់ដែលគេសំរេចយកវិធីសាស្រ្តដែលផ្តោតការយកចិត្តទុកដាក់លើមីក្រូសេដ្ឋកិច្ច គឺថាការអប់រំនៅតាមសាលាពាណិជ្ជកម្មបានធ្វើឲ្យបាត់បង់ចំណងទាក់ទងរបស់ខ្លួនទៅនឹងទីផ្សារពលកម្ម និងផលិតកម្ម ។

ភាគច្រើននៃនិស្សិត ៣០០០០ នាក់ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលនៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈវិលត្រឡប់ទៅភូមិកំណើតរបស់គេវិញ ឬបន្តការសិក្សានៅឧត្តមសិក្សាប្រសើរជាងធ្វើការនៅក្នុងផ្នែកជំនួញ ដែលពួកគេបានចំណាយពេលវេលា ៣ ឆ្នាំ ដើម្បីរៀនសូត្រ ។

# ២.៤ ការរៀនមួយជីវិត

## បណ្ដុះបណ្ដាលវិជ្ជាជីវៈ

សាលាមួយក្នុងចំណោមសាលាទាំង ៥០ ដែលត្រូវបានជ្រើសរើសសំរាប់តំណាក់កាលដំបូងនៃគម្រោងគឺមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ Mac Auliffe ស្ថិតនៅ Quito ជាទីក្រុងដែលមានប្រជាជនក្រីក្រជាងគេ ។ មណ្ឌលនេះមានគ្រូចំនួន ២០ នាក់ និងសិស្សចំនួន ២៦០ នាក់ ។

ចាប់តាំងពីខែកញ្ញា សិស្សដែលរៀនផ្នែកកាត់ដេរសំលៀកបំពាក់នឹងចាប់ផ្ដើមកាត់ដេរសំលៀកបំពាក់ឯកសណ្ឋាន សំលៀកបំពាក់ស្ត្រី ខោវ និងអាវជាច្រើនម៉ូតផ្សេងៗទៀតសំរាប់ទីផ្សារ Ecuadore ។

សាលាមួយទៀតដែលសង្ឃឹមថានឹងបានចូលរួមក្នុងគម្រោងគឺមណ្ឌលអប់រំ Trilingual នៅ Brisas del Estero ជាតំបន់ក្រីក្រនៃ Durn ជាតំបន់ជាយក្រុងនៃ Guayaquil ។

មណ្ឌល Atahualpa ត្រូវបានសាងសង់ឡើងដោយជនជាតិដើម ដែលផ្លាស់ទីលំនៅទៅកាន់តំបន់ឆ្នេរ និងផ្ដល់ការអប់រំជាភាសាអេស្បាញ អង់គ្លេស និង Quechua។ ទោះបីជាវាមិនមែនជាមណ្ឌលសំរាប់មនុស្សពេញវ័យក៏ដោយ ក៏គេសង្ឃឹមថាសាលានេះនឹងបានចូលរួមក្នុងគម្រោង ហើយផ្ដល់ឱកាសឲ្យសិស្សរបស់ខ្លួនបានកាងារធ្វើពេលរៀនចប់ ។

Jos Valla ជាគ្រូបង្រៀននៅមណ្ឌល Atahualpa បានមានប្រសាសន៍ថា សាលាយើងកំពុងខ្វះថវិកា ហើយថវិការបស់ខ្លួនកំពុងតែធ្លាក់ចុះដោយសារយើងមិនបានទទួលជំនួយពីរដ្ឋ ឬពីស្ថាប័នឯកជនណាមួយនោះទេ ។ សិស្សជាជនជាតិឥណ្ឌា ជនជាតិស្បែកខ្មៅ និងចំរុះជាតិ ។ លោក Valla និយាយថា បុគ្គលិកដែលមានជនជាតិដើមបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យចង់ជួយលើកកំពស់សង្គម ហើយផ្ដល់ការអប់រំដោយមិនគិតថ្លៃ។ បើតាមប្រសាសន៍នាយកសាលា Atahualpa គឺលោក Manuel Cujilema គោលបំណងរបស់សាលាយើងគឺដើម្បីឆ្លុះបញ្ចាំងគំនិតដែលថាពួកជនជាតិដើមអាចចាត់ចែងមុខជំនួញតូចតាចរបស់គេបាន ហើយមិនចាំបាច់មានអ្នកណាមកជួយកាន់កាប់គ្រប់គ្រងនោះទេ ។

នៅកន្លែងដទៃទៀតដូចជា Casa Campesina (Peasant House) of Cayambe, north of Quito ស្ត្រីចន្ទួន ៧០ នាក់បង្កើតមុខរបរដេរប៉ាក់តូចមួយ តាំងពី ១៥ ឆ្នាំមុនម្ល៉េះ បន្ទាប់ពីពួកគេមួយចំនួនធំបានបញ្ចប់ការសិក្សានៅសាលាពាណិជ្ជកម្ម ។

# ២.៤ ការរៀនមួយជីវិត

## បណ្ដុះបណ្ដាលវីជ្ជាជីវៈ

បច្ចុប្បន្ននេះ ផ្ដល់ការបណ្ដុះបណ្ដាលដល់ទាំងអ្នកដែលមានមិក្រូសហគ្រាសរួចហើយ និងអ្នកដែលបំរុងនឹងចាប់ផ្ដើមបើកមុខរបរថ្មី ។

នៅខែមករា គេបានរៀបចំសិក្ខាសាលាមួយ ដោយឲ្យកសិករក្មេងៗចំនួន ២៤ នាក់ចូលរួមដែលមានអាយុចាប់ពី ១៥ ដល់ ២៥ ឆ្នាំ ដែលកំពុងតែទទួលការបណ្ដុះបណ្ដាលដើម្បីក្លាយជាជាងសោរ ជាងម៉ាស៊ីន និងជាងឈើ ដោយលក់ផលិតផលផលិតបាននៅពេលពួកគេកំពុងរៀន ។ នៅត្រឹមខែមីនាសាលាចាប់ផ្ដើមបង្រៀនកសិករអំពីបច្ចេកទេសកសិកម្មទំនើបៗ ។

អត្ថបទនេះត្រូវរក្សាសិទ្ធិគ្រប់យ៉ាង ហើយការដកស្រង់ត្រូវមានច្បាប់អនុញ្ញាតពី និងយល់ព្រមពី Inter Press Service.